នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 07-Jun-2013, 15:26
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះសាលាដំបូង: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់មេធាវីការពារក្តី ខៀវ សំផន សុំឲ្យទទួលយកភស្តុតាង អនុលោមតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង (E290)

---

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម យូ ឧត្តរា
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រមបម្រុង ធូ មុន្នី
ចៅក្រមបម្រុង Judge Claudia FENZ

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
ជនជាប់ចោទ:
នួន ជា
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ
លោក Michiel PESTMAN
លោក Victor Koppe
លោក គង់ សំអុន
លោកស្រី Anta GUISSÉ
លោក Arthur VERCKEN
លោក Jacques VERGÈS

## I. សេចក្ដីផ្ដើម

១. មេធាវីការពារក្ដី ខៀវ សំផន ("មេធាវីការការពារក្ដី") បានដាក់សំណើមួយដោយសុំឱ្យទទួលយកសារទូរលេខការទូតចំនួន១៤ ពីរដ្ឋាភិបាលអាមេរិក អនុលោមតាមវិធាន៨៧(៤)[1] នៃវិធានផ្ទៃក្នុង ("សំណើ")។ សហព្រះរាជអាជ្ញា សូមជំទាស់នឹងការទទួលយកសារទូរលេខចំនួនពីរ ក្នុងចំណោមសារទូរលេខទាំងអស់ ដោយផ្អែកលើមូលដ្ឋានថា សារទូរលេខទាំងពីរនេះមិននាំមកនូវការស្វែងរកការពិតទេ និងត្រូវបានច្រានចោលដោយវិធាន៨៧(៣)។

## II. ប្រវត្តិនីតិវិធី

២. នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៣ Wikileaks បានបញ្ចេញមូលដ្ឋានទិន្នន័យដែលអាចស្រាវជ្រាវតាមប្រព័ន្ធអ៊ិនធ័រណិត អំពីការប្រាស្រ័យទំនាក់ទំនងការទូតរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក[2]។ មួយផ្នែកនៃមូលដ្ឋានទិន្នន័យនេះ (database) មានឈ្មោះថា "The Kissinger Cables" ធ្វើដោយ Wikileaks រួមមានសារទូរលេខមួយចំនួនពីថ្ងៃទី១ មករា ១៩៧៣ ដល់ថ្ងៃទី៣១ ធ្នូ ១៩៧៦ ដែលបានបញ្ចេញជាសាធារណៈដោយរដ្ឋាភិបាលសហរដ្ឋអាមេរិក ប៉ុន្តែមិនទាន់មាននៅក្នុងទម្រង់អាចឱ្យគេស្រាវជ្រាវរកបានលើអ៊ិនធ័រណិតជាផ្លូវការណ៍នៅឡើយ។ ផ្នែកទីពីរនៃមូលដ្ឋានទិន្នន័យនេះ មានផ្ទុកភ័ស្តុតាងផ្សេងៗដែលទទួលបានពីប្រភពផ្សេងទៀត មានឈ្មោះថា "Cablegate" ធ្វើដោយ Wikileaks ដែលបើយោងតាម Wikileaks ភាគច្រើនបំផុត គឺក្នុងរយៈកាលពីឆ្នាំ ២០០៣ ដល់ ឆ្នាំ២០១០។ ភាគច្រើននៃឯកសារក្នុង "Cablegate" មិនទាន់បានបញ្ចេញជាសារធារណៈជាផ្លូវការណ៍ទេ។

៣. នៅថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានដាក់សំណើមួយសុំឱ្យទទួលយកសារទូរលេខចំនួន២៦ ដែលរកបានដោយប្រើមូលដ្ឋានស្រាវជ្រាវតាម Wikileaks ដែលសារទូរលេខទាំងអស់នេះ យកពីក្នុងឯកសារដែលបានបញ្ចេញជាសាធារណៈនៅក្នុង "The Kissinger Cable"[3]។

៤. នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១៣ មេធាវីការពារក្ដីបានឆ្លើយតប ដោយជំទាស់នឹងការទទួលយកសារទូរលេខទាំង២៦ ដោយអះអាងថា ឯកសារទាំងនោះមានភាពលំអៀង និងមិនសមស្របសម្រាប់ការបញ្ជាក់ពីអង្គហេតុនានា អនុលោមតាមវិធាន៨៧(៣)(គ) និង/ឬ មិនជាប់ពាក់ព័ន្ធ

---

[1] **E290** សំណើសុំដាក់បញ្ចូលសារទូរលេខតាមផ្លូវទូតអាមេរិកទៅក្នុងការពិភាក្សាដេញដោល អនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង, ៣០ ឧសភា ២០១៣ ("សំណើ")។

[2] អាចរកបានតាមរយៈ Available at: http://search.wikileaks.org/plusd/ .

[3] **E282** សំណើរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន៨៧ (៤)នៃវិធានផ្ទៃក្នុង ស្ដីពីសារទូរលេខតាមផ្លូវទូតរបស់ សហរដ្ឋអាមេរិក ដែលទើបតែអាចរកបាននាពេលថ្មីៗនេះ, ២២ មេសា ២០១៣។

អនុលោមតាមវិធាន៨៧(៣)(ក)។ មេធាវីការពារក្តីតវ៉ាបន្ថែមថា សិទ្ធិក្នុងការការពារក្តី នឹងទទួលរងនូវការខូចខាតដោយសារការទទួលយកភស្តុតាង នៅក្នុងដំណាក់កាលនៃការជំនុំជម្រះក្តីនេះ[4]។

៥. នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១៣ មេធាវីការពារក្តីបានដាក់សំណើនេះ ដោយសុំឱ្យទទួលសារទូរលេខចំនួន១៤ នៃសារទូរលេខការទូតរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ដែលទទួលបានពីមូលដ្ឋានទិន្នន័យដែលអាចស្រាវជ្រាវបានរបស់ Wikileaks។ សារទូរលេខចំនួន១២ ក្នុងចំណោមសារទូរលេខទាំងអស់ យកពីមូលដ្ឋានទិន្នន័យ "The Kissinger Cable" និងចំនួន២ យកចេញពីមូលដ្ឋានទិន្នន័យ "Cablegate"។ សារទូរលេខចំនួន២ចុងក្រោយនេះ គឺពីឆ្នាំ២០០៦ ដល់ ២០០៧។

៦. មេធាវីការពារក្តីអះអាងថា សារទូរលេខទាំងនេះអាចទទួលយកបាន ដោយផ្អែកលើមូលដ្ឋានដូចតទៅ៖ សារទូរលេខចំនួន៤ ពាក់ព័ន្ធនឹងកិត្តិស័ព្ទរបស់ ខៀវ សំផន[5] សារទូរលេខចំនួន៤ ពាក់ព័ន្ធនឹងការបង្ហាញពីអំណាចរបស់ ខៀវ សំផន នៅមុន និងក្រោយឆ្នាំ១៩៧៥[6] សារទូរលេខចំនួន៧ ពាក់ព័ន្ធនឹងការបង្ហាញពីសម្តេចឪ នរោត្តម សីហនុ មានជម្លោះបុគ្គលប្រឆាំងនឹងមេដឹកនាំសាធារណរដ្ឋខ្មែរ[7] និងសារទូរលេខ២ ទៀត ពាក់ព័ន្ធនឹងការចោទប្រកាន់ចំពោះការជ្រៀតជ្រែកផ្នែកនយោបាយ និងអំពើពុករលួយនៅ អ.វ.ត.ក[8]។

៧. សហព្រះរាជអាជ្ញាសូមធ្វើការឆ្លើយតបដូចតទៅ។ ដោយមិនមានការយល់ព្រមលើតម្លៃភស្តុតាងណាមួយ សហព្រះរាជអាជ្ញាមិនជំទាស់នឹងការទទួលយកសារទូរលេខទាំង១២ ក្នុងរយៈកាលពីឆ្នាំ១៩៧៣-១៩៧៥ នេះទេ។ សហព្រះរាជអាជ្ញាសូមជំទាស់នឹងការទទួលយកសារទូរលេខចំនួន២ ពីឆ្នាំ២០០៦ និងឆ្នាំ២០០៧ ដោយសារមិនពាក់ព័ន្ធ និងច្រំដែលៗមិនសមស្របសម្រាប់ការបញ្ជាក់ពីអង្គហេតុនានាដែលសារទូរលេខទាំងនេះចង់បញ្ជាក់នោះទេ និង/ឬដោយសារឥតបានការ។

## III. អំណះអំណាង

៨. ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងអាចទទួលយកភស្តុតាងថ្មី "ដែលអង្គជំនុំជម្រះយល់ឃើញថាមានប្រយោជន៍ដើម្បីបញ្ជាក់ការពិត ផ្អែកតាមលក្ខណៈវិនិច្ឆ័យទូទៅសម្រាប់ការទទួលយកភស្តុតាងដូចមានចែងក្នុងវិធាន ៨៧(៣)"[9]។ ដើម្បីឱ្យ

[4] **E282/1** ឧបសម្ព័ន្ធ ក។

[5] **E290** សំណើ, កថាខណ្ឌទី១១-១៦។

[6] **E290** សំណើ, កថាខណ្ឌទី១៧-២១។

[7] **E290** សំណើ, កថាខណ្ឌទី២២-២៥។

[8] **E290** សំណើ, កថាខណ្ឌទី២៦-៣៤។

[9] **E217/1**អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ចម្លើយតបទៅនឹងសំណើសុំដាក់ឯកសារថ្មីមួយទៅក្នុងសំណុំរឿង ដោយអនុលោម តាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E217), ៧ សីហា ២០១២, កថាខណ្ឌ ២។

ច្បាស់“ភស្តុតាងទាំងអស់ត្រូវតែស្របទៅតាមលក្ខណៈវិនិច្ឆ័យទូទៅសម្រាប់ទទួលយកជាភស្តុតាង ដែល មានចែងក្នុងវិធាន ៨៧(៣)(ក)-(ង) នៃវិធានផ្ទៃក្នុង”[10]។

៩. វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង ចែងថា អង្គជំនុំជម្រះសាលាដំបូងអាចបដិសេធចំពោះពាក្យសុំឲ្យពិនិត្យភស្តុតាង បើយល់ឃើញថាៈ

ក-មិនជាប់ពាក់ព័ន្ធ ឬ ជាការស្នើសុំជាន់គ្នា
ខ-មិនអាចរកបានក្នុងរយៈពេលសមស្របណាមួយ
គ-មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលជាគោលដៅនៃការស្នើសុំពិនិត្យភស្តុតាង
ឃ-ច្បាប់មិនអនុញ្ញាត ឬ
ង-មានចេតនាពន្យារកិច្ចដំណើរការនីតិវិធី ឬគ្មានប្រយោជន៍។

**ក. សារទូរលេខឆ្នាំ ១៩៧៣-១៩៧៦**

១០. ដូចដែលបានថ្លែងមកដូច្នោះ សហព្រះរាជអាជ្ញាមិនជំទាស់ទៅនឹងការទទួលយកសារទូរលេខចំនួន ១២ នៅក្នុងរយៈកាលឆ្នាំ ១៩៧៣-១៩៧៦ នោះទេ[11] ប៉ុន្តែមិនយល់ព្រមទៅនឹងតម្លៃជាភស្តុតាង ណាមួយ របស់សារទូរលេខទាំងនោះទេ។ លើសពីនេះ សហព្រះរាជអាជ្ញា មិនយល់ព្រម ទៅនឹងភាពត្រឹមត្រូវនៃការចាត់ថ្នាក់របស់មេធាវីការពារក្តីទៅលើ ខ្លឹមសារ ឬ សារៈសំខាន់ នៃសារទូរ លេខ ទាំងនោះឡើយ[12]។

**ខ. សារទូរលេខឆ្នាំ ២០០៦-២០០៧**

១១. សហព្រះរាជអាជ្ញា សូមជំទាស់ ទៅនឹងភាពអាចទទួលយកបាន នៃសារទូរលេខចំនួន២ នៅឆ្នាំ២០០៦[13] និង ឆ្នាំ២០០៧[14] ដោយមកពីវា មិនមានប្រយោជន៍ដើម្បីបញ្ជាក់ការពិត មិនមានការពាក់ព័ន្ធ មានលក្ខណៈជាន់គ្នា មិនសមស្របសម្រាប់បញ្ជាក់អង្គហេតុដែលមេធាវីការពារក្តីចង់បញ្ជាក់ និង/ឬ វាគ្មានប្រយោជន៍។ មេធាវីការពារក្តីអះអាងថា សារទូរលេខទាំងនេះ មានការពាក់ព័ន្ធក្នុងការបង្ហាញអំពីការជ្រៀតជ្រែក និង អំពើពុករលួយ នៅ អ.វ.ត.ក។ ដូច្នេះ ជាបញ្ហាពីដំបូងមក សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា អង្គជំនុំជម្រះនេះ ធ្លាប់បានសម្រេច ពីមុនមកថា មតិរបស់អ្នកខាងក្រៅ “ពាក់ព័ន្ធនឹងភាពយុត្តិធម៌នៃកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ... ពុំមាន

[10] **E190** សេចក្តីសម្រេចទាក់ទិននឹងឯកសារថ្មីៗ និងបញ្ហាពាក់ព័ន្ធដទៃទៀត, ៣០ មេសា ២០១២, កថាខណ្ឌ ១៨។

[11] ឯកសារភ្ជាប់ **E290.1.1-E290.1.12**។

[12] **E290** សំណើ, ត្រង់កថាខណ្ឌ ១១-២៥។

[13] **E290.1.14** សារទូរលេខ ឆ្នាំ២០០៦។

[14] **E290.1.13** សារទូរលេខ ឆ្នាំ២០០៧។

តម្កើជាភស្តុតាង និងពុំសមស្របដើម្បីបញ្ជាក់អង្គហេតុ ដែលសេចក្តីសន្និដ្ឋានទាំងនោះចង់បញ្ជាក់ឡើយ"[15]។

*i. ថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០០៦៖ "តុលាការខ្មែរក្រហមកំពុងកសាងភិមសា" - សារទូរលេខ ១៤*

១២. មេធាវីការពារក្តីបាន ចោទប្រកាន់ថា សារទូរលេខនេះបានបង្ហាញអំពីការជ្រៀតជ្រែកខាងនយោបាយនៅ អ.វ.ត.ក ពីព្រោះវាបានរាយការណ៍ថា មនុស្សពីរនាក់ដែលត្រូវមកបម្រើការនៅក្នុងការិយាល័យសហព្រះរាជអាជ្ញា គឺត្រូវគេ "គិតថា មានភាពលម្អៀង និង ងាយស្រួលក្នុងការទទួលឥទ្ធិពលពីរដ្ឋាភិបាល"[16]។ ទីមួយ សេចក្តីថ្លែងនេះគឺ មិនអាចទទួលយកបានទេ ពីព្រោះដោយហេតុថា មតិដែលមិនបានស្បថដេញដោលរបស់ភាគីទីបី (ដោយសារវាត្រូវបានប្រាប់ទៅកម្មសិក្សាការីម្នាក់)[17] ប្រឆាំងនឹងបុគ្គលដែលពុំមានឈ្មោះនោះវាគឺ មិនសមស្របសម្រាប់បញ្ជាក់ពីអ្វីដែលមេធាវីការពារក្តីចង់បញ្ជាក់ គឺការបញ្ជាក់ពីការជ្រៀតជ្រែកនោះទេ។ លើសពីនេះ វាមិនបានបង្ហាញថា បុគ្គលដែលពុំមានឈ្មោះទាំងពីររូបនោះធ្លាប់បានធ្វើសកម្មភាពអ្វីខ្លះ ឬពុំនោះ សោតទេ ធ្លាប់បានប្រឆាំងនឹងជនជាប់ចោទ ដោយមានមូលដ្ឋាននៅលើភាពលម្អៀងខាងនយោបាយដែលបានលើកឡើងចោទប្រកាន់នោះ ឬមួយក៏ថា រដ្ឋាភិបាលមានគោលបំណងជ្រើសរើស ពួកគេមកដោយមានការព្យាយាមជះឥទ្ធិពលយ៉ាងជាក់ស្តែងទៅលើពួកគេនោះក៏ទេដែរ។ ទីពីរ សេចក្តីថ្លែងនេះ គឺ មិនអាចទទួលយកបាន ពីព្រោះវាមិនមានការពាក់ព័ន្ធ។ បើទោះជា ឯកសារដែលបានបង្ហាញពីការជ្រៀតជ្រែកជាក់ស្តែង ទៅលើសមាជិកនានា (ដែលបានគូសបញ្ជាក់ថាមិនមែនដូច្នោះទេ) ក៏ ការិយាល័យសហព្រះរាជអាជ្ញា ដែលជាភាគីមួយនៃកិច្ចដំណើរការនីតិវិធីនេះ ក៏ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់អង្គជំនុំជម្រះនានានៃ សាលាក្តីមួយនេះ ហើយមិនធ្លាប់ត្រូវបានគេរកឃើញថាមានការជាប់ទាក់ទិននៅក្នុងការប្រព្រឹត្តណាមួយ ដែលបានប៉ះពាល់ដោយប្រឆាំងទៅនឹងសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្តី ដោយយុត្តិធម៌នោះឡើយ។ ការិយាល័យសហព្រះរាជអាជ្ញា បានថ្លែងដោយសង្កត់សេចក្តីថា ខ្លួនតែងតែប្រព្រឹត្តដោយមានលក្ខណៈឯករាជ្យ និងដោយសេចក្តីព្យាយាម ព្រមទាំងបានសម្របសម្រួលលើភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះនេះ នៅគ្រប់រឿងក្តី និងនៅគ្រប់ដំណាក់កាល ថែមទៀតផង - ដោយរួមទាំង នៅក្នុងសវនាការលើសំណុំរឿងមួយនេះផង ដែលគេអាចបង្ហាញបានថាមានភាពយុត្តិធម៌ចំពោះជនជាប់ចោទ។

១៣. មេធាវីការពារក្តីក៏បានចោទប្រកាន់ដែរថា សារទូរលេខនេះបង្ហាញឱ្យឃើញពីចេតនាមិនត្រង់តាងនាមឱ្យមជ្ឈមណ្ឌលឯកសារកម្ពុជា(DC-Cam) ហើយដែលអាស្រ័យហេតុនេះគឺជាប់ទាក់ទងទៅ

---

[15] **E217/1** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ចម្លើយតបទៅនឹងសំណើសុំដាក់ឯកសារថ្មីមួយទៅក្នុងសំណុំរឿង ដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង (ឯកសារ E217), ៧ សីហា ២០១២, កថាខណ្ឌ ៣។

[16] **E290** សំណើ, ត្រង់កថាខណ្ឌ ២៧។

[17] **E290.1.14** សារទូរលេខ ឆ្នាំ២០០៦, ត្រង់កថាខណ្ឌ ២។

នឹងឯកសារដែលទទួលបានមកពីពួកគាត់[18]។ ឯកសារនេះមិនសក្តិសមសម្រាប់បង្ហាញភស្តុតាងអំពីអ្វីដែលមេធាវីការពារក្តីមានបំណងចង់បង្ហាញនោះឡើយ ព្រោះខ្លឹមសារនៅក្នុងសារទូរលេខនេះមិនបានបង្ហាញឲ្យឃើញអំពីចេតនាមិនត្រង់តាងនាមឲ្យ មជ្ឈមណ្ឌលឯកសារកម្ពុជា DC-Cam នោះឡើយ។ សារទូរលេខនេះគ្រាន់តែចោទប្រកាន់ថាមជ្ឈមណ្ឌលឯកសារកម្ពុជា DC-Cam មាន “ការរារែកក្នុងការបញ្ជូនឯកសារទាំងនេះមកឲ្យ អ.វ.ត.ក ” ដោយមិនមានការបញ្ជាក់ពីមូលហេតុ និងបានរៀបរាប់អំពីពាក្យ *ពង្រាង* អនុស្សរណៈយោគយល់គ្នាមួយ[19]។ បន្ថែមពីលើនេះ ឯកសារនេះ មិនសក្តិសមសម្រាប់យកមកបង្ហាញភស្តុតាងអំពីអង្គហេតុនានា ដែលមេធាវីការពារក្តី បានអះអាងថា ឯកសារនេះសម្រាប់បង្ហាញភស្តុតាង ពីព្រោះការជ្រៀតជ្រែក គឺខុសយ៉ាងច្បាស់ណាស់។ នៅក្នុងរយៈពេលប្រាំពីរឆ្នាំនៃដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក គ្មានភស្តុតាងអំពីការរារែកណាមួយពីសំណាក់មជ្ឈមណ្ឌលឯកសារកម្ពុជា DC-Cam ក្នុងការធ្វើសហប្រតិបត្តិការជាមួយតុលាការត្រូវបានបង្ហាញឲ្យឃើញនោះឡើយ។ តាមការពិត ដូចដែលបានបង្ហាញតាមរយៈសក្ខីកម្មរបស់លោកនាយក[20] និងលោកនាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា DC-Cam[21] នៅចំពោះមុខអង្គជំនុំជម្រះនេះមជ្ឈមណ្ឌលឯកសារកម្ពុជា DC-Cam បានផ្តល់សិទ្ធិដល់គ្រប់ភាគីទាំងអស់រួមទាំងមេធាវីការពារក្តីផង អ្នកដែលអាចឆ្លៀតពេល ទៅរកសេវាកម្មរបស់ មជ្ឈមណ្ឌលឯកសារកម្ពុជា DC-Cam ដើម្បីចូលទៅពិនិត្យមើលបណ្ណសាររបស់ខ្លួនដោយបើកចំហរ និងដោយពុំមានការហាមឃាត់ឡើយ។ ភស្តុតាងស្តីពីការជួយឧបត្ថម្ភដល់មេធាវីការពារក្តីនេះ មិនត្រូវបានតវ៉ាប្រឆាំងដោយមេធាវីការពារក្តីឡើយ នៅក្នុងពេលដែលមន្ត្រីជាន់ខ្ពស់បំផុតពីររូបរបស់ មជ្ឈមណ្ឌលឯកសារកម្ពុជា DC-Cam បានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង។

១៤. មេធាវីការពារក្តីថែមទាំងបានជជែកថា សារទូរលេខនេះមានការជាប់ទាក់ទងពីព្រោះនៅក្នុងនោះមានសរសេរថា លោក Steve Heder ធ្លាប់បានបម្រើការងារឲ្យការិយាល័យសហព្រះរាជអាជ្ញា ហើយព្រោះតែ លោក Steve Heder នឹងត្រូវកោះហៅឲ្យចូលមកធ្វើជាសាក្សី[22]។ ក៏ប៉ុន្តែ ព័ត៌មាននេះមិនជាប់ទាក់ទង និង/ឬ មានភាពច្រំដែល ព្រោះមិនមានការប្រកែកតវ៉ាថា លោក Steve Heder នៅត្រង់ចំណុចមួយនោះ ធ្លាប់បានបម្រើការងារឲ្យការិយាល័យសហព្រះរាជអាជ្ញា ហើយមេធាវីការពារក្តីខកខានមិនបានចង្អុលបង្ហាញភស្តុតាងអំពីតើអង្គហេតុនេះ បង្ហាញអំពីការជ្រៀតជ្រែក ឬអំពើពុករលួយយ៉ាងដូចម្តេចខ្លះ?។

---

[18] ឯកសារលេខ **E290** សំណើ, ត្រង់កថាខណ្ឌទី៣០។

[19] ឯកសារលេខ **E290** សំណើ, ត្រង់កថាខណ្ឌទី៧។

[20] ឯកសារលេខ **E1/37.1** ប្រតិចារិក ចុះថ្ងៃទី១ ខែកុម្ភៈ ២០១២។ ឯកសារលេខ E1/38.1 ប្រតិចារិក ចុះថ្ងៃទី២ ខែកុម្ភៈ ២០១២។ ឯកសារលេខ E1/39.1 ប្រតិចារិក ចុះថ្ងៃទី៦ ខែកុម្ភៈ ២០១២។

[21] ឯកសារលេខ **E1/31.1** ប្រតិចារិក ចុះថ្ងៃទី២៣ ខែមករា ២០១២។ ឯកសារលេខ E1/32.1 ប្រតិចារិក ចុះថ្ងៃទី២៤ ខែកុម្ភៈ ២០១២។ ឯកសារលេខ E1/33.1 ប្រតិចារិក ចុះថ្ងៃទី២៥ ខែកុម្ភៈ ២០១២។ 12.

[22] ឯកសារលេខ **E290** សំណើ, ត្រង់កថាខណ្ឌទី៣៣។

ii. *ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧៖ "តុលាការខ្មែរក្រហមបានបំពេញបានសម្រេចតាមបទដ្ឋានគំរូនៃភាពគួរឲ្យជឿទុកចិត្ត" - សារទូរលេខលេខ១៣*

១៥. មេធាវីការពារក្ដីបានចោទប្រកាន់ថា សារទូរលេខនេះ គួតែត្រូវបានទទួលយក ពីព្រោះសារទូរលេខនេះបានផ្ដល់នូវភស្ដុតាងអំពីការជ្រៀតជ្រែកផ្នែកនយោបាយនឹងអំពើពុករលួយនៅក្នុង អវតក ។ សហព្រះរាជអាជ្ញា សូមជូនមតិថា សារទូរលេខនេះមិនគួរត្រូវបានទទួលយកទេ ព្រោះមិនមានការជាប់ទាក់ទង និង/ឬ ព្រោះវាមិនសក្តិសមសម្រាប់យកមកបង្ហាញភស្ដុតាងតាមអ្វីដែលមេធាវីការពារក្ដីមានបំណងចង់បង្ហាញនោះឡើយ។

១៦. ដើម្បីគាំទ្រចំពោះការលើកឡើងអះអាងរបស់ខ្លួនដោយខុសរបៀបនោះ មេធាវីការពារក្ដីបានកត់សម្គាល់ជាដំបូងថា ជាក់ស្ដែងសារទូរលេខបានសរសេរថា រដ្ឋាភិបាលសហរដ្ឋអាមេរិក "ជឿថា[] បរិយាកាសនយោបាយនៅក្នុងប្រទេសកម្ពុជានឹងអនុញ្ញាតឲ្យ...មានការជំនុំជម្រះក្ដីមួយដោយគ្មានការជ្រៀតជ្រែកគួរឲ្យកត់សម្គាល់"[23]។ អាស្រ័យហេតុនេះគឺសារទូរលេខនិយាយផ្ទុយពីការលើកឡើងអះអាងដែលមេធាវីការពារក្ដីបានចោទប្រកាន់ថា សារទូរលេខបានគាំទ្រ ដែលហេតុដូច្នេះគឺមិនសក្តិសមជាភស្ដុតាងសម្រាប់បង្ហាញអំពីការជ្រៀតជ្រែកនោះឡើយ។

១៧. ការលើកឡើងអះអាងជាបន្ទាប់មកទៀតរបស់មេធាវីគឺ អត្ថបទខ្លីដែលមកពីក្នុងសារទូរលេខដែលរៀបរាប់អំពីលិខិតមួយច្បាប់របស់អង្គការសហប្រជាជាតិផ្ញើជូនព្រះបរមរាជវាំង ដែលត្រូវបានអះអាងថា បានសរសេរ"ថា អវតក នឹងប្រកាន់យ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍របស់ខ្លួន ហើយមិនចូលរួមពាក់ព័ន្ធនៅក្នុង"[24] បង្ហាញឲ្យឃើញពីអំពើពុករលួយ និង/ឬ ការជ្រៀតជ្រែកដែលជាការសម្ដែងឆាកល្ខោនឡើយ។ ប៉ុន្តែសារជាថ្មីម្ដងទៀតសេចក្ដីថ្លែងនេះបើសិនជាមានមែននោះ គឺវាបង្ហាញឲ្យឃើញអំពីឯករាជ្យភាពរបស់ អវតក ទៅវិញទេ មិនមែនការជ្រៀតជ្រែកឡើយ។

១៨. សេចក្ដីយោងជាបន្ទាប់មកទៀត របស់មេធាវី គឺការរៀបរាប់នៅក្នុងសារទូរលេខ អំពីការធ្វើសវនកម្មមួយរបស់អង្គការ UNDP ថា "ការពិពណ៌នាទូទៅដោយត្រួសៗអំពីការចោទប្រកាន់ពីអំពើពុករលួយនៅក្នុងការជួលបុគ្គលិកជាតិកម្ពុជាដើម្បីមប្រើការងារនៅ អ.វ.ត.ក"[25]។ ក៏ប៉ុន្តែ

---

[23] ឯកសារលេខ **E290** សំណើ, ត្រង់កថាខណ្ឌទី២៧។

[24] ឯកសារលេខ **E290.1.13** , ត្រង់កថាខណ្ឌទី៨។

[25] ឯកសារលេខ **E290** សំណើ, ត្រង់កថាខណ្ឌទី២៩ (មេធាវីការពារក្ដីបានយោងខុសទៅលើសារទូរលេខលេខ១០ នៅក្នុងការដាក់ឯកសាររបស់ខ្លួន, ប៉ុន្តែបានលើកសំអាងទៅលើសារទូរលេខលេខ១៣)។ ឯកសារ **E290.1.13** សារទូរលេខឆ្នាំ ២០០៧, ត្រង់កថាខណ្ឌទី៩។

មេធាវីការពារក្តីមិនបានបង្ហាញឱ្យឃើញអំពីថា តើការចោទប្រកាន់នេះមានជាប់ទាក់ទងគ្នាបែបដូចម្តេចខ្លះទៅនឹងសិទ្ធិរបស់ជនជាប់ចោទនៅក្នុងសំណុំរឿងលេខ០០២/០១នោះឡើយ[26]។

១៩. ជាចុងក្រោយ មេធាវីការពារក្តីបានចោទប្រកាន់ថា សារទូរលេខបានបង្ហាញថាព័ត៌មានដែលជាការសម្ងាត់បំផុត ត្រូវបានផ្តល់ជូនទៅស្ថានទូតរបស់សហរដ្ឋអាមេរិកនៅភ្នំពេញ[27]។ ក៏ប៉ុន្តែ ជាថ្មីម្តងទៀត មេធាវីការពារក្តីខកខានមិនបានចង្អុលបង្ហាញភស្តុតាង អំពីថា បើសិនជាការពិតមែននោះ តើការចោទប្រកាន់នឹងមានការជាប់ទាក់ទងបែបដូចម្តេចខ្លះទៅនឹង ផលប្រយោជន៍របស់កូនក្តីខ្លួននៅក្នុងសំណុំរឿងលេខ០០២/០១?។

## VI. សំណើ

២០. អាស្រ័យដោយមូលហេតុដូចបានលើកឡើងខាងលើ សហព្រះរាជអាជ្ញា សូមស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងមេត្តាបដិសេធការទទួលយកនូវឯកសារលេខ E290.1.13 និង E290.1.14៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក Andrew CAYLEY**<br>សហព្រះរាជអាជ្ញា | | [signature] |

[26] សូមមើល D158/5/3/15 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើសំណើបំពេញកិច្ចស៊ើបសួរលើកទី៨ប់មួយរបស់ នួនជា ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ២០០៩ កថាខណ្ឌ៥៩។

[27] ឯកសារលេខ **E290** សំណើ, ត្រង់កថាខណ្ឌទី៣២។